# វិសោធនកម្មច្បាប់បោះឆ្នោតកំហិតសិទ្ធិសេរីភាពក្រុមជំទាស់ដែលអវត្តមានក្នុងការបោះឆ្នោត



រូបភាពឯកសារ៖ នាយករដ្ឋមន្ត្រីកម្ពុជាលោក Hun Sen ទះដៃអំឡុងពិធីគម្រប់ខួបទី៧១របស់គណបក្សប្រជាជននៅទីស្នាក់ការកណ្ដាលក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី ២៨ មិថុនា ឆ្នាំ២០២២។

ចែករំលែក

ភ្នំពេញ — វិសោធនកម្មច្បាប់បោះឆ្នោត ដែលធ្វើឡើងតាមការស្នើសុំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកំណត់ផ្ដន្ទាទោសលើជនទាំងឡាយណាដែលបង្កការរារាំង ឬញុះញង់មិនឱ្យពលរដ្ឋទៅបោះឆ្នោត ឬណែនាំពលរដ្ឋឱ្យគូសសន្លឹកឆ្នោតចោល។ ជនឬគណបក្សនយោបាយអាចប្រឈមការផាកពិន័យជាប្រាក់ចាប់ពី៥លានទៅដល់

៣០លានរៀល ដែលមិនទាន់គិតពីទោសព្រហ្មទណ្ឌ និងឈានទៅដក ហូតសិទ្ធិនយោបាយជាដើម។ នេះបើតាមសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត ចុះថ្ងៃទី១៤ ខែមិថុនា ដែលវីអូអេទទួលបាន។

វិសោធនកម្មច្បាប់បោះឆ្នោតនេះ ក៏បានកំណត់ដាក់លាក់ក្នុងការកំហិតសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត បើសិនបុគ្គលណាម្នាក់មិនបានទៅបោះឆ្នោត ដែលលោក ហ៊ុន សែន មានគោលដៅកំហិតសិទ្ធិឈរឈ្មោះរបស់គណបក្សជំទាស់។
លោក ហ៊ុន សែន បញ្ជាក់កម្មវត្ថុទៅកាន់ប្រធានរដ្ឋសភា លោក ហេង សំរិន ថាសំណើសុំពិនិត្យ និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មបោះឆ្នោត ដោយចាត់ទុកជាការប្រញាប់ គឺអនុម័តឱ្យបានមុនការបោះឆ្នោតជាតិមកដល់។ នេះបើតាមលិខិតរបស់លោក ហ៊ុន សែន ដែលដាក់ទៅរដ្ឋសភា ភ្ជាប់ជាមួយវិសោធនកម្មច្បាប់នេះ។

លោកនាយករដ្ឋមន្ត្រីបញ្ជាក់ថាការស្នើកែទម្រង់«សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត»នេះ គឺដើម្បីពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកដឹកនាំនយោបាយនៅកម្ពុជា ដែលផ្អែកលើដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស និងយោងតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ និងតាមច្បាប់ជាធរមាននានា។



រូបឯកសារ៖ សមាជិករដ្ឋសភាដែលមកពីគណបក្សប្រជាជនកម្ពុជាចូលរួមកិច្ចប្រជុំមួយ នៅរដ្ឋសភាជាតិកម្ពុជា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០២១។ (AFP/រដ្ឋសភាជាតិកម្ពុជា)

សេចក្តីព្រៀងច្បាប់នៃវិសោធនកម្មច្បាប់បោះឆ្នោតបានកំណត់ថា ចំពោះប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះ ជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបោះឆ្នោតសកលបានចំនួន២លើកចុងក្រោយជាប់គ្នា។ នេះមានន័យថាមន្ត្រីគណបក្សជំទាស់ត្រូវតែទៅបោះឆ្នោតនាខែកក្កដាខាងមុខ និងបោះឆ្នោតឃុំសង្កាត់នាឆ្នាំ២០២៧ ទើបអាចឈរឈ្មោះជាតំណាងរាស្ត្រនៅក្នុងការបោះឆ្នោតជាតិនាឆ្នាំ២០២៨។

ដោយឡែកចំពោះប្រជាពលរដ្ឋខ្មែរដែលមានបំណងឈរឈ្មោះ ជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវ

បោះឆ្នោតសកលបានចំនួន១លើកចុងក្រោយ ដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើកលែងតែករណីដែលមានការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះ មានមូលហេតុសមស្រប ហើយត្រូវបំពេញលក្ខខណ្ឌផ្សេងៗមួយចំនួនទៀត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាស្ថាប័ន ដែលអាចកំណត់បែបបទ លក្ខខណ្ឌ និងនីតិវិធី ព្រមទាំងមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោត។ នេះមានន័យថាមន្ត្រីគណបក្សជំទាស់ត្រូវតែទៅបោះឆ្នោតនាខែកក្កដាខាងមុខ ទើបអាចឈរឈ្មោះជាក្រុមប្រឹក្សាឃុំសង្កាត់នៅក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋាន នាឆ្នាំ២០២៧។

ក្រៅពីនេះ វិសោធនកម្មច្បាប់បោះឆ្នោតនេះ បានកំណត់ដាក់ទោសទៅលើជនទាំងឡាយណាដែលធ្វើសកម្មភាពរារាំង ឬញុះញង់ប្រជាពលរដ្ឋមិនឱ្យទៅបោះឆ្នោត ឬមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ឬបង្កការអុកឡុកពាក់ព័ន្ធដំណើរការបោះឆ្នោតផ្សេងៗទៀត ដែលនឹងត្រូវផាកពិន័យជាទឹកប្រាក់ពី៥លានរៀល ទៅដល់៣០លានរៀល និងអាចត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់រយៈពេល៥ឆ្នាំ ដែលមិនទាន់គិតពីទោសព្រហ្មទណ្ឌ។ ចំណែកការណែនាំឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬក៏ធ្វើឱ្យខូចសន្លឹកឆ្នោត ក៏ត្រូវបានកំណត់នៅក្នុងវិសោធនកម្មច្បាប់បោះឆ្នោតនេះផងដែរ។

ការធ្វើវិសោធនច្បាប់បោះឆ្នោតនេះ គឺជាគំនិតផ្តួចផ្តើមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកថាការធ្វើច្បាប់នេះ ដើម្បីឆ្លើយតបទៅនឹងយុទ្ធនាការ WIFI របស់ក្រុមប្រឆាំង ដែលមិនចង់ទៅបោះឆ្នោត ឬទៅបោះឆ្នោតដោយគូសសន្លឹកឆ្នោតចោល។

កាលពីថ្ងៃទី១៩ ខែមិថុនា ក្នុងកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងារក្រុមការងាររដ្ឋាភិបាលនីតិកាលទី៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថាមានតែប្រើ«វិធានការច្បាប់»ប៉ុណ្ណោះ ទើបអាចកម្ចាត់ក្រុមអ្នកនយោបាយប្រឆាំង ដែលគ្រោងធ្វើយុទ្ធនាការ Wifi «មិនចង់ទៅបោះឆ្នោត ឬទៅបោះឆ្នោតដោយគូសសន្លឹកឆ្នោតចោល»។

លោកថ្លែងថា៖ «ប៉ុន្តែដល់អ្នកឯងធ្វើហួស គឺយើងគ្មានជម្រើសណាក្រៅពីវិធានការច្បាប់ទេ។ ហើយបើច្បាប់ចេញហើយ អ្នកឯងប្រថុយជាមួយច្បាប់ វាមានតែគុកព្រៃស ត្រពាំងផ្លុង ព្រះវិហារ។ អាគុកហ្នឹងគេធ្វើ សម្រាប់ដាក់មនុស្សខូចតាស»។

លោក ហ៊ុន សែន បន្ថែមថានេះជាការសម្លាប់សិទ្ធិនយោបាយរបស់បុគ្គលណាដែលមិនទៅបោះឆ្នោតនាខែកក្កដាខាងមុខនេះ។

អ្នកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្លែងថាបើការធ្វើវិសោធនកម្មច្បាប់ គ្រាន់តែឆ្លើយតបទៅនឹងស្ថានការណ៍នយោបាយ ដោយមិនឆ្លើយតបទៅនឹងគោលការណ៍សិទ្ធិមនុស្ស នោះវានឹងធ្វើឱ្យប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យកម្ពុជា និងកាន់តែធ្វើឱ្យសេរីភាពនយោបាយកម្ពុជាកាន់តែរួមតូច ស្របពេលគណបក្សភ្លើងទៀនបាត់បង់សិទ្ធិចូលរួមការបោះឆ្នោត ហើយសកម្មជនតែងតែរងការយាយីផ្សេងៗ។

អ្នកស្រីថ្លែងថា៖ «ការបន្ថែមនៃការធ្វើវិសោធនកម្មនេះទៀតសោត វានឹងធ្វើឱ្យស្ថានភាពនយោបាយនេះ កាន់តែរួមតូចទៅៗ។ ទោះបីយើងឃើញហើយ ក្នុងចេតនានៃបញ្ញាក់ធ្វើវិសោធនកម្មនេះ ក្នុងន័យដើម្បីធានាដល់គោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស អីយ៉ាងណាក៏ដោយ ប៉ុន្តែបើយើងមើលពីខ្លឹមសារនៃការស្នើឱ្យមានវិសោធនកម្មនេះ គឺមិនបានឆ្លើយតបនឹងគោលដៅនោះទេ»។



អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជាវាគ្មិននៅក្នុងពិធីអបអរសាទរទិវាសេរីភាពសារព័ត៌មានលើកទី៣០ នៅរាជធានីភ្នំពេញ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣។ (លាស់ លីបលីប/វីអូអេ)

បើតាមអ្នកស្រី ចក់ សុភាព នេះមិនមែនជាលើកទី១ទេ ដែលរដ្ឋាភិបាលកម្ពុជាធ្វើវិសោធនកម្មច្បាប់ ព្រោះកាលពីឆ្នាំ២០១៣ រដ្ឋាភិបាលកម្ពុជា ក៏បានធ្វើវិសោធនកម្មច្បាប់ផងដែរ ដែលពេលនោះឈានទៅរំលាយគណបក្សប្រឆាំងដ៏ធំ គឺគណបក្សសង្គ្រោះជាតិ។

អ្នកស្រីបន្ថែមថាការធ្វើវិសោធនកម្មច្បាប់អ្វីមួយ គួរតែអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្ស ដើម្បីធានាដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសត្រូវសិក្សា ត្រួតពិនិត្យ វិភាគ និងប្រមូលធាតុចូលឱ្យបានគ្រប់គ្រាន់ ទើបអាចឱ្យគ្រប់ភាគីទទួលយកបាន និងដើម្បី

អាចឆ្លើយតបទៅតាមគោលការណ៍នីតិរដ្ឋ។

ក្រៅពីនេះ អ្នកស្រីកត់សម្គាល់ថាខ្លឹមសារមួយចំនួនក្នុងវិសោធនកម្មច្បាប់បោះឆ្នោតនេះ មានភាពទូលាយច្រើន ដែលងាយប៉ះពាល់ ឬធ្វើបាត់បង់សិទ្ធិឈរឈ្មោះរបស់បេក្ខជនមួយចំនួន។

អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក លោក ស៊ឹង សែនករុណា ប្រាប់វីអូអេថាវិសោធនកម្មច្បាប់បោះឆ្នោតនេះ គួរតែធ្វើឡើងដោយផ្អែកតាមបទដ្ឋានសិទ្ធិមនុស្ស និងស្របតាមគោលការណ៍ប្រទេសលទ្ធិប្រជាធិបតេយ្យ។ លោកបន្ថែមថាច្បាប់នេះមិនគួរមានលក្ខណៈបម្រើផលប្រយោជន៍ក្រុម ឬបុគ្គលណាមួយ ដើម្បីគោលដៅនយោបាយនោះឡើយ។

លោកថ្លែងថា៖ «ប្រសិនជាបង្កើតឡើងក្នុងការឆ្លើយតបទៅនឹងសកម្មភាពណាមួយ ជាលក្ខណៈនយោបាយ យើងដឹងហើយ ចង់មិនចង់ ទាំងសហគមន៍ជាតិ អន្តរជាតិគេមានការចោទប្រកាន់ ថាការបង្កើតហ្នឹងគ្រាន់តែជាការធ្វើឡើងក្នុងការតតាំងទៅលើវិធីសាស្ត្រ ឬក៏យុទ្ធសាស្ត្រ គេហៅថាទប់ទល់ជាមួយរឿងនយោបាយស្ថានភាពនយោបាយនាពេលបច្ចុប្បន្នតែប៉ុណ្ណឹង»។

អ្នកនាំពាក្យគណបក្សភ្លើងទៀន លោក គីមសួរ ភីរិទ្ធ យល់ថាសេចក្តីព្រាងវិសោធនកម្មច្បាប់បោះឆ្នោត មានគោលដៅដាក់សម្ពាធ និងធ្វើទុក្ខបុកម្នេញក្រុមជំទាស់ ព្រមទាំងគណបក្សប្រឆាំង។ លោកបន្ថែមថាច្បាប់នេះនឹងមិនមានការឱ្យតម្លៃជាសកលពីសំណាក់ប្រជាពលរដ្ឋឡើយ។

គួរបញ្ជាក់ថារដ្ឋសភានឹងបើកសម័យប្រជុំពេញអង្គ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងវិសោធនកម្មច្បាប់បោះឆ្នោតនេះ នៅថ្ងៃទី២៣ ខែមិថុនា។ នេះបើតាមលោក ហ៊ុន សែន៕